THE SCHOOL DISTRICT OF PHILADELPHIA

**ការិយាល័យនាយកសាលា**
440 North Broad Street
Philadelphia, PA 19130

ថ្ងៃទី 6 ខែសីហា ឆ្នាំ 2020

សូមគោរពជូនក្រុមគ្រួសារសិស្សSchool District of Philadelphia

ខ្ញុំសរសេរលិខិតនេះដើម្បីចែករំលែកបច្ចុប្បន្នភាពស្តីអំពីកិច្ចប្រឹងប្រែងកែលម្អអគារសិក្សារបស់យើង។

ចាប់តាំងពីការបិទអគារសិក្សារបស់យើងនៅខែមីនាឆ្នាំ 2020 ដោយសារការរាតត្បាតនៃវីរុស COVID-19 District បានបង្កើនកិច្ចប្រឹងប្រែងកែលម្អអគារសិក្សារបស់ខ្លួន។ យើងបានធ្វើការវិនិយោគទឹកប្រាក់ជិត 264 លានដុល្លារនៅក្នុងការកែលម្អអគារសិក្សាចំនួនទូទាំង 61 សាលារៀន រួមមាន៖

- 61 គម្រោងនៅរដ្ឋធានី ដូចជាការប្តូរដំបូល ការប្តូរ/ការជួសជុលម៉ាស៊ីនកម្តៅទឹក ការបង្កើនគុណភាពនៃប្រព័ន្ធ HVAC និងប្រព័ន្ធអគ្គិសនី និងការជួសជុលបន្ទប់ទឹក
- ការធ្វើទំនើបកម្មថ្នាក់រៀន 147 បន្ទប់ចំនួន 11 សាលារៀនដែលគាំទ្រដល់កិច្ចប្រឹងប្រែងរបស់យើងក្នុងការពង្រឹងអក្ខរកម្មឲ្យបានលឿន
- ការងារលាបថ្នាំ និងការងារបូកចំនួន 24 គម្រោង ដែលនាំឲ្យសាលា(Certified Lead Safe) របស់យើងកើនឡើងសរុបរហូតដល់110 សាលារៀន
- ការវាយតម្លៃលើការបង្កើតចរន្តខ្យល់ចេញចូលគ្រប់គ្រាន់ និងការជួសជុលបង្អួច
- ការយកចេញវត្ថុធាតុមានផ្ទុកអាបេស្តូជាង 250,000 ហ្វីត មានដូចជាឥដ្ឋការ៉ូបាត និងអ៊ីសូឡង់បំពង់

ព័ត៌មានលម្អិតបន្ថែមទៀតសម្រាប់គម្រោងនីមួយៗគឺមាននៅលើគេហទំព័រកម្មវិធីរដ្ឋធានី (Capital Programs) នៅទីនេះ។ គេហទំព័រនឹងត្រូវបានធ្វើបច្ចុប្បន្នភាពជាញឹកញាប់នៅពេលដែលគម្រោងបានបញ្ចប់ ហើយគម្រោងថ្មីត្រូវបានរៀបចំកាលវិភាគ។

យើងដឹងថាមានការងារច្រើនទៀតដែលត្រូវធ្វើ។ ការចាប់ផ្តើមឆ្នាំសិក្សាថ្មី ដោយមានសិស្សទាំងអស់ចូលរៀនតាមប្រព័ន្ធឌីជីថលពីចម្ងាយក្នុងអំឡុងពេលកែដាក់ពិន្ទុកលើកទីមួយ (រហូតដល់ថ្ងៃទី 17 ខែវិច្ឆិកា) អនុញ្ញាតឲ្យយើងបង្កើនកិច្ចប្រឹងប្រែងរបស់យើងក្នុងការកាត់បន្ថយសារធាតុអាបេស្តូនិងកែតម្រូវនៅក្នុងសាលារៀនចំនួន 28 សាលា។ គម្រោងទាំងនេះត្រូវបានជ្រើសរើស ពីព្រោះគម្រោងទាំងនេះអាច បញ្ចប់នៅត្រឹមថ្ងៃទី 17 ខែតុលា ដែលអាចធ្វើការសម្អាត និងរៀបចំអគារឲ្យរួចរាល់សម្រាប់ការសិក្សាផ្ទាល់ក្នុងថ្នាក់នៅត្រឹមថ្ងៃទី 17 ខែវិច្ឆិកា ប្រសិនបើចាំបាច់។

យើងនៅតែប្តេជ្ញាចិត្តបន្តការងាររបស់យើងក្នុងការផ្តល់ជូនអគារសិក្សាដែលមានសុវត្ថិភាព និងគួរជាទីស្វាគមន៍ដែលសិស្ស និងបុគ្គលិកយើងសមនឹងទទួលបាន។ ក្នុងករណីការសិក្សាតាមប្រព័ន្ធនៅតែបន្តហួសពីរយៈពេលកែដាក់ពិន្ទុលើកទីមួយ យើងនឹងបន្តបង្កើនកិច្ចប្រឹងប្រែងកែលម្អរបស់យើងតាមគម្រោងថវិកា។ គួររំឭកថា មតិរបស់អ្នកមានសារៈសំខាន់ពេលនិយាយពីការតស៊ូមតិ ដើម្បីការផ្តល់ថវិកាដែល District របស់យើងត្រូវការជាខ្លាំង។ អ្នកអាចចូលមើលគេហទំព័រphilasd.org/fundourschools ដើម្បីរកធនធាន និងស្វែងយល់បន្ថែមអំពីរបៀបដែលអ្នកអាចផ្តល់ជំនួយ។

សូមថ្លែងអំណរគុណអ្នកដែលបានបន្តការសហការនៅពេលយើងធ្វើការជាមួយគ្នាដើម្បីត្រៀមរៀបចំឆ្នាំសិក្សាឲ្យមានសុវត្ថិភាព និងទទួលជោគជ័យ!

ដោយក្តីរាប់អានដ៏ស្មោះស្ម័គ្រ

William R. Hite Jr., Ed.D.
នាយកសាលា
The School District of Philadelphia